សង្ខេបរឿង៖ ផ្កាស្រពោន

ផ្កាស្រពោន ! ...។ កំសត់មែន! ផ្កាស្រពោន !..!។ ពាក្យបីម៉ាត់នេះជាឈ្មោះប្រលោម លោកមួយរបស់លោក នូ-ហ៊ាច អ្នកនិពន្ធខ្មែរក្នុងស.វ ទី២០។ បើយើងធ្លាប់ដឹងថា អ្នកនិពន្ធជាតិ យើងចូលចិត្តប្រដូចនារីទៅ នឹងផ្កាយើងយល់បានដោយងាយ ថាផ្កាស្រពោនគឺ ជារឿងនារី រងទុក្ខដោយ ឥត សង្ស័យឡើយ។ មែនហើយ ! ផ្កាស្រពោនជារឿងស្នេហាដ៏ខ្លោចឱព របស់អ្នកកំលោះ ប៊ុន ធឿន សិស្សអនុវិទ្យាល័យព្រះស៊ី សុវត្ថិ ហើយនិងនាងក្រមុំ វិធាវី ផ្កាកុលាបនៅបាត់ដំបង។ សេចក្តីស្នេហា របស់គូកំសត់ទាំង ពីរនេះ មិនមែនកើតឡើងដោយចៃដន្យ ឬដោយចិត្ត និងចិត្តទេ គឺមាតាបិតានៃសាមីខ្លួនទាំងពីរបានបណ្តុះ ស្នេហានេះអោយមានរូបរាងឡើង តាំងពីកុមារភាពមកម៉្លេះ។ វិធាវី ជាកូនក្រមុំបណ្តូលចិត្តរបស់ យាយ នួន មានទីលំនៅ នៅភូមិវត្តពោធិក្នុង (ក្រុងបាត់ដំបង)។ ឪពុករបស់នាងដែលធ្លាប់តែពេញចិត្តនិងលើក នាងអោយទៅ ប៊ុន ធឿន នោះបាន ទទួលអនិច្ចកម្មទៅហើយ។ សព្វថ្ងៃនេះ ក្នុងផ្ទះរបស់នាង ក្រៅអំពី នាងនិងមាតារបស់នាងដែលមានវ័យចាស់បន្តិចទៅហើយនោះ គេឃើញមានតែ បាវបំរើម្នាក់មានអាយុ ច្រើនជាងយាយ នួនទៅទៀត។ បាវបំរើនោះឈ្មោះយាយ ផៃ។ យាយ ផៃ ស្រឡាញ់ពេញចិត្តនឹងនាង វិធាវីណាស់ដែរ គាត់ សប្បាយ ឬ គាត់ព្រួយតាមការប្រែប្រួលនៃទឹកភ័ក្ររបស់នាង វិធាវីទាំងអស់។ ប៊ុន- ធឿន សង្សារវិសេសរបស់នាងវិធាវី ក៏មានទីលំនៅក្នុងខេត្ត បាត់ដំបងដែរ ប៉ុន្តែនៅឆ្ងាយអំពីទីក្រុងគឺនៅ ដល់ទៅភូមិកំពង់ព្រះឯណោះ។ ឪពុកម្តាយសព្វថ្ងៃ នៅរស់ទាំងអស់ចឹក ប៊ុនថន រកស៊ីធ្វើជំនួញ ស្រូវ ចេះ តែខាតរៀងរាល់ឆ្នាំ។ ឆ្នាំនេះគាត់ធ្លាក់ខ្លួនក្រហើយ។ ភរិយារបស់គាត់ព្រមទាំងនាងសោភ័ណ ជាបុត្រី បានខំធ្វើការឥតសំចៃកំលាំង ដើម្បី សន្សំប្រាក់ ទុកសងបំណុលគេកាលដែល ចឹក ប៊ុន-ថន ខ្ចីប្រាក់គេយក ទៅទិញស្រូវ ហើយដែលជួបគ្រោះថ្នាក់ លិចទូកប៉ុកចាយកណ្តាល ទន្លេ សាប។ ប៊ុន-ធឿន ជាកូនប្រុស ក្នុងពេលវិស្សមកាល ត្រឡប់ទៅភូមិកំណើតវិញ ក៏បាននិយាយអង្វរឪពុកថា ខ្លួនឈប់ទៅរៀនទៀត ហើយ ព្រោះ ស្ថានភាពរបស់គ្រួសារកាន់តែដុនដាបណាស់ទៅហើយ ខ្លួនត្រូវនៅផ្ទះដើម្បីជួយធ្វើការ ឪពុកម្តាយវិញ។ ប៊ុន-ថន ជាឪពុកដ៏ប្រសើរ មិនព្រមអោយ កូនឈប់រៀនទេ។ គាត់និយាយពន្យល់កូន លុះត្រាតែកូនសុខចិត្តទៅរៀនតាមបង្គាប់របស់គាត់។ ចាប់តាំងពីបានដំណឹងច្បាស់ថា គ្រួសាររបស់ចឹក ប៊ុន-ថន ធ្លាក់ខ្លួនក្រក្នុងទុព្វលភាព លោកយាយ នួន ខំ ពន្យល់ណែនាំនាងវិធាវីជាកូនអោយលះបង់សេចក្តីស្នេហាអំពីប៊ុន-ធឿន។ នាងវិធាវីអន់ចិត្តនឹង ម្តាយណាស់ តែនាងមិនហ៊ានតពាក្យសំដី អ្វីដែល អាចនាំអោយអ្នកផងទាំងពួងថ្កោលទោសថានាងជានារី អកត្តញ្ញូបានឡើយ។ នាងចេះតែសោកសង្រេងនឹកទៅដល់ ប៊ុន-ធឿនទាំងយប់ទាំងថ្ងៃ។ ថ្ងៃមួយ ១៤ខែសូយ៉េត ប៊ុន-ធឿន បានទៅលេងឯទីក្រុងបាត់ដំបង បានឆ្លៀតឱកាសទៅជួបនាងវិធាវីបានមួយ ភ្លែត។ នាងក្រមុំបានអោយរូបថត មួយសន្លឹកមក ប៊ុន-ធឿន ដើម្បីទុកជាអនុស្សាវរីយ៍ ហើយបានផ្តែផ្តាំ ប៊ុន-ធឿនអោយខំយកចិត្តទុកដាក់ក្នុងការសិក្សា ដើម្បីអោយបានសំរេចលទ្ធ ផលព្រមទាំងសន្យាថា នាង នៅរង់ចាំ ប៊ុន-ធឿនជានិច្ច។ ឥឡូវនេះ បវេសនកាលថ្មីបានមកដល់ទៀតហើយ។ ប៊ុន-ធឿន ក៏បានចូលទៅនៅក្នុងអនុវិទ្យាល័យស៊ីសុវត្ថិ ទៀត។ ពេលដែលប៊ុន-ធឿនកំពុងតែបើកសៀវភៅសិក្សា លោកយាយនួន បានបង្ខំចិត្ត វិធាវី ជាសង្សារអោយរៀបការនឹងអ្នកកំលោះ ណៃ-ស៊ិត កូនប្រុសរបស់លោក ណៃ-ស៊ាន ជាអ្នកមាន សម្បត្តិស្តុកស្តម្ភ ក្នុងខេត្តបាត់ដំបង។

វិធាវីស្អប់ខ្ពើមណៃ-ស៊ិត ជាទីបំផុត ហើយនាងខឹងនឹងម្តាយនាង ក៏មិនតិចដែរ ប៉ុន្តែនាងមិនហ៊ាននិងរឹងរូសនឹងម្តាយនាងទេ។ នាងសរសេរសំបុត្រប្រាប់រឿងរ៉ាវហ្នឹង អោយប៊ុន-ធឿន ដឹងព្រមទាំងប្រកាសថា នាង មិនព្រមរៀបការជាមួយនឹងបុរសដទៃណាក្រៅពី ប៊ុន-ធឿន ឡើយ។ កំលោះ ប៊ុន-ធឿន ផ្ញើសំបុត្រមកអង្វរ វិធាវីអោយសុខចិត្ត រៀបការជាមួយកំលោះ ណៃ-ស៊ិតទៅ ព្រោះគេជាអ្នកមាន គេអាចរកសុភមង្គលមកអោយគ្រួសារបានដោយងាយ។ ទុកណាប៊ុន-ធឿនអង្វរយ៉ាងនេះក៏ដោយ ក៏នាងវិធាវីមិនព្រមតាមបំណងម្តាយនាងទេ ព្រោះនាង ដឹងថា ប៊ុន-ធឿនស្រឡាញ់នាងខ្លាំងណាស់ មួយវិញទៀតនាងដឹងថា អ្នកកំលោះ ណៃ-ស៊ិត ជាបុរស កន្ទ្រង់ បុរសដើរបំផ្លាញព្រហ្មចារី របស់ស្រីក្រមុំជា ច្រើនរូបណាស់មកហើយ។ មួយថ្ងៃៗនាងវិធាវីយំសោក ឥតដែលខាន។ រាងកាយនាងកាន់តែស្គមបន្តិចម្តងៗ យាយនួនឃើញដូច្នេះ ក៏នាំនាងទៅ លេងអង្គរវត្ត ខេត្តសៀមរាប ទៅសំណាក់នៅផ្ទះមិត្តភ័ក្រ្តរបស់ខ្មោចប្តីគាត់ឈ្មោះ លោកបេង-ជុន និងនាង ស៊ី-ម៉ារ៉ា។ ទៅឃើញអង្គរល្អវិចិត្រក៏ ដូច ឃើញខ្ទមជរាអញ្ចឹង នាងវិធាវីគ្មានកាញញឹមបន្តិចសោះ។ លុះនាងឃើញព្រះពុទ្ធរូបមួយអង្គធំ នាងក៏អុជធូបបួងសួងសុំអោយព្រះជួយនាង អោយ រួចពីក្រញាំរបស់ ណៃ-ស៊ិត។ បន់ព្រះមិនទាន់ផុតពីម៉ាត់ផងស្រាប់តែ ណៃ-ស៊ិត បរឡានទៅដល់ ហើយដើរទៅឈរក្បែរនាងភ្លាម។ នាងខឹងខ្លាំង ទៅជាឈឺ។ វិធាវី គ្រុនអស់ពីរ បីថ្ងៃនៅខេត្តសៀមរាប។ យាយនួន ឃើញកូនឈឺធ្ងន់ក៏នាំ នាងវិលត្រឡប់មកស្រុកកំណើតវិញ។ ថ្ងៃរៀបការកាន់ តែ សសៀរចូលជិតមកដល់ហើយ ជំងឺរបស់នាង វិធាវីកាន់តែជាបធ្ងន់ឡើងៗជាលំដាប់។ យាយនួន ហើយនឹងនាងថូ ជាម្តាយរបស់ ណៃ-ស៊ិត បាន ទៅ អញ្ជើញហោរា អារក្សអ្នកតា និងគ្រូអាចារ្យ មកស្រោចទឹកឥតដែលខាន។ ជម្ងឺគ្រុននៅតែដដែល។ និយាយពី ប៊ុន-ធឿនវិញ។ អ្នកកំលោះនេះនឹកដល់វិធាវីគ្រប់ពេលវេលាដែរ ប៉ុន្តែអ្នកស៊ូឱបសេចក្តី ទុក្ខដើម្បី អោយស្រីសង្សារបានសុខនឹងថ្កុំថ្កើងមុខមាត់។ ក្នុងឱកាសបុណ្យចូលឆ្នាំ អ្នកវិលទៅសំរាកឯ ភូមិកំណើត ទៅលេងព្រៃជាមួយនិងតាសូ ហើយនឹង អ្នកស្រុក ស្រីប្រុសជាច្រើនទៀតដើម្បីបំបាត់ទុក្ខ។ អ្នកស្រុកអ្នកភូមិកំពង់ព្រះចូលព្រៃរនាម ដើម្បីរកទឹកឃ្មុំ ចំណែក ប៊ុន-ធឿនចូលព្រៃរនាមដើម្បី កំចាត់ជម្ងឺ ទ្រូងដែលកើតឡើងពីរឿងជីវិត។ លុះអ្នកវិលពីព្រៃរនាមមកវិញ ក្រោយដែលបានតយុទ្ធយកជ័យជំនះអំ ពីពួកចោរ អ្នកសុំលាឪពុកម្តាយ ទៅលេងក្រុងបាត់ដំបង។ អ្នកដើរបង្ហួសទៅដល់វត្តពោធិក្នុង ស្រាប់តែ ឃើញមនុស្សអ៊ូរអរកុះករទាំងក្មេងទាំងចាស់។ អ្នកចូលទៅដល់ស្រាប់តែ ឃើញរូបថតនាងវិធាវីនៅប្រេប នឹងក្តារមឈូស។ វិធាវីស្លាប់ហើយ ! ។ នាង ស្លាប់ព្រោះរឿងវិបត្តិស្នេហា។ វិធាវីស្លាប់ទៅ បានទុកចិញ្ចៀនមួយវង់ និងសំបុត្រមួយអោយប៊ុន-ធឿន ជាគូរសង្សារបណ្តូលចិត្ត។